# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

បង្កើតគណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងការពារជាតិ | | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងផែនការ | | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | | សមាជិក |

| | |
|---|---|
| ១៣- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៧- ឯកឧត្តម **សុខុម ឆតឧបន្តមុនី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកប្រចាំការ |
| ១៨- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តពាក់ព័ន្ធ | សមាជិក |

**មាត្រា ២**.-

គណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា មានភារកិច្ច ៖

- ដឹកនាំ តម្រង់ទិស និងសម្របសម្រួលការងារស្វែងរកប្រភពហិរញ្ញប្បទានសម្រាប់ការសាងសង់កំណាត់ផ្លូវដែកពីបាត់ដឹង - ស្ទួល និងការអភិវឌ្ឍបណ្តាញផ្លូវដែកថ្មី និងការធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែកទូទាំងប្រទេស
- លើកសំណើជូន រាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចលើសកម្មភាពអនុវត្ត រួមមាន ៖
  + ដោះស្រាយហិរញ្ញប្បទានទាំងក្នុងប្រទេស និងក្រៅប្រទេស
  + ដោះស្រាយផលប៉ះពាល់ដីធ្លី និងផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ក្នុងគម្រោងសាងសង់
  + ការដោះមីន និងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះតាមបណ្តោយផ្លូវដែកដែលត្រូវសាងសង់
- ដោះស្រាយ និងសម្របសម្រួលរាល់បញ្ហាការងារសាងសង់ ការសិក្សា និងការធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនានា និងលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ៣**.-

គណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីគណៈរដ្ឋមន្ត្រី ។

ប្រធានគណៈកម្មាធិការអាចអញ្ជើញតំណាងពីក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬអ្នកបច្ចេកទេសដទៃទៀតមកជួបប្រជុំតាមការកំណត់ ។

**មាត្រា ៤**.-

គណៈកម្មាធិការនេះ អាចបង្កើតគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារមួយចំនួន តាមការចាំបាច់។

**មាត្រា ៥**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ